10 Shenton Way
#15-08, MAS Building
Singapore 079117
T: +65 6323 9844
F: +65 6223 8187
www.amro-asia.org

# ទស្សនវិស័យសេដ្ឋកិច្ចតំបន់អាស៊ានបូកបីឆ្នាំ២០១៧

# ខ្លឹមសារគន្លឹះ

## ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងបញ្ហាប្រឈម

១. ទស្សនវិស័យសេដ្ឋកិច្ចតំបន់អាស៊ានបូកបីមានស្ថានភាពល្អប្រសើរ គាំទ្រដោយការងើបឡើងវិញនៃពាណិជ្ជកម្ម និងការវិនិយោគសកល។ កំណើនសេដ្ឋកិច្ចក្នុងតំបន់នេះ ត្រូវបានព្យាករថានឹងមានកំណើន ៥,២ ភាគរយ នៅក្នុងឆ្នាំ ២០១៧ ហើយអតិផរណាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ទោះបីជាពិភពលោកកំពុងស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជាក៏ដោយ។

២. កំណើនសេដ្ឋកិច្ចរបស់ប្រទេសធំជាងគេពីរក្នុងតំបន់ ពោលគឺប្រទេសចិន និងជប៉ុន នៅបន្តមានស្ថិរភាព និងភាពរឹងមាំ។ ប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ក្នុងតំបន់ (Emerging markets) ដែលរួមមាន កូរ៉េ អាស៊ាន-៥ (ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហ្វីលីពីន សិង្ហបុរី និង ថៃ) និងវៀតណាម នៅបន្តរក្សាបាននូវភាពធន់ (Resilience) ទោះបីជាទីផ្សារហិរញ្ញវត្ថុសកលកំពុងស្ថិតក្នុងស្ថានភាពប្រែប្រួលខ្លាំងក្លាក៏ដោយ។ ចំណែកឯសេដ្ឋកិច្ចនៃបណ្តាប្រទេសកំពុងអភិវឌ្ឍក្នុងតំបន់ (Developing economies) ដែលរួមមានប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ក៏នៅបន្តមានកំណើន និងកំពុងទាញយកផលប្រយោជន៍ពីសមាហរណកម្មតំបន់ផងដែរ។

៣. កំណើនសេដ្ឋកិច្ចក្នុងតំបន់នឹងនៅតែបន្តគាំទ្រដោយតម្រូវការក្នុងស្រុក ព្រមទាំងមានការទ្រទ្រង់ពីការងើបឡើងវិញនៃការនាំចេញនាពេលថ្មីៗនេះ។ ប្រទេសនីមួយៗនឹងនៅតែបន្តទាញយកផលប្រយោជន៍ពីសមាហរណកម្មតំបន់ផ្នែកពាណិជ្ជកម្ម និងវិនិយោគ។

៤. ការកើនឡើងនៃការគាំពារពាណិជ្ជកម្ម (Trade protectionism) ការរឹតបន្តឹងស្ថានភាពហិរញ្ញវត្ថុសកល ការកើនឡើងនៃអតិផរណា និងភាពប្រែប្រួលទីផ្សារហិរញ្ញវត្ថុកាន់តែខ្លាំងក្លា គឺសុទ្ធតែជាហានិភ័យដែលអាចជះឥទ្ធិពលអវិជ្ជមានដល់ទស្សនវិស័យកំណើនសេដ្ឋកិច្ចសកល ដែលរួមទាំងសេដ្ឋកិច្ចតំបន់អាស៊ានបូកបីផងដែរ។

៥. អ្នករៀបចំគោលនយោបាយ គួរតែយកចិត្តទុកដាក់ជាអាទិភាពទៅលើស្ថិរភាពហិរញ្ញវត្ថុ ជាជាងការផ្តោតតែទៅលើកំណើនសេដ្ឋកិច្ច។ ទោះបីជាលទ្ធភាពនៃការអនុវត្តគោលនយោបាយបានថយចុះ ហើយបរិយាកាសគោលនយោបាយសកលកាន់តែមានភាពមិនប្រាកដប្រជា ទ្រនាប់ទុនបម្រុងបរទេសក្នុងតំបន់នៅតែមានបរិមាណច្រើនគ្រប់គ្រាន់។

AMRO
ASEAN +3 MACROECONOMIC RESEARCH OFFICE

10 Shenton Way
#15-08, MAS Building
Singapore 079117
T: +65 6323 9844
F: +65 6223 8187
www.amro-asia.org

## ប្រធានបទស្នូល: សេដ្ឋកិច្ចតំបន់អាស៊ានបូកបីរយៈពេល២០ឆ្នាំ បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុអាស៊ី

៦. វិបត្តិហិរញ្ញវត្ថុអាស៊ី (AFC) គឺជាព្រឹត្តិការណ៍ដែលបានធ្វើឱ្យអ្នករៀបចំគោលនយោបាយមានការកែប្រែចក្ខុវិស័យចំពោះការគ្រប់គ្រង និងដោះស្រាយវិបត្តិនានា។ AFC ក៏បាននាំមកនូវការបង្កើតការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី (ASEAN+3 Macroeconomic Research Office - AMRO) និងការបង្កើតកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (Chiang Mai Initiative Multilateralisation - CMIM)។

៧. មេរៀន និងបទពិសោធន៍ដែលទទួលបានពី AFC នៅតែមានសារសំខាន់មកដល់បច្ចុប្បន្ននេះ÷ ការផ្តោតគោលនយោបាយទៅលើហានិភ័យដែលកើតចេញទីផ្សារហិរញ្ញវត្ថុ និងលំហូរចេញនៃមូលធន ការចង្អុលបង្ហាញពីល្បឿន និងឥទ្ធិពលនៃការរីករាលដាលរវាងបណ្តាសេដ្ឋកិច្ចនានា និងការកំណត់ពីសារសំខាន់ចាំបាច់នៃការអនុវត្តក្របខ័ណ្ឌគោលនយោបាយប្រកបដោយភាពបត់បែន និងអាចឆ្លើយតបកាន់តែឆាប់រហ័សជាងមុនដើម្បីទប់ទល់នឹងការប៉ះទង្គិចពីខាងក្រៅ (External shocks)។

៨. អំឡុងពេលមួយទសវត្សរ៍បន្ទាប់ពី AFC (១៩៩៧ - ២០០៦) សេដ្ឋកិច្ចក្នុងតំបន់ដែលបានទទួលរងវិបត្តិ បានកសាងមូលដ្ឋានកំណើនសេដ្ឋកិច្ចឡើងវិញ តាមរយៈកំណែទម្រង់គោលនយោបាយចម្បងៗមួយចំនួនដូចជា÷ នយោបាយរូបិយវត្ថុដែលមានវិន័យជាងមុន ដោយងាកទៅប្រកាន់យករបបអត្រាប្តូរប្រាក់ដែលមានភាពបត់បែន (Flexible exchange rate regime) ក្របខ័ណ្ឌបទប្បញ្ញត្តិដែលមានភាពតឹងរឹងជាងមុន ការពង្រឹងសារពើពន្ធ (Fiscal Consolidation) និងកំណែទម្រង់ហិរញ្ញវត្ថុ និងសាជីវកម្ម។ ទន្ទឹមនឹងនោះ ទ្រនាប់ទុនបម្រុងអន្តរជាតិក៏ត្រូវបានបង្កើនជាបន្តបន្ទាប់ផងដែរ ។

៩. មូលដ្ឋានសេដ្ឋកិច្ចរឹងមាំ និងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចបានល្អប្រសើរជាងមុន បានអនុញ្ញាតឱ្យតំបន់អាស៊ាន-បូកបី បញ្ចៀសបាននូវការរងឥទ្ធិពលខ្លាំងក្លាពីវិបត្តិហិរញ្ញវត្ថុសកល (GFC)។ ក្នុងអំឡុងពេលចាប់ពីឆ្នាំ២០០៧មកទល់បច្ចុប្បន្ននេះ តំបន់អាស៊ានបូកបីបានទាញយកផលប្រយោជន៍ពីការកើនឡើងនៃសមាហរណកម្មផ្នែកពាណិជ្ជកម្ម និងវិនិយោគតំបន់ ព្រមទាំងអាចគ្រប់គ្រងហានិភ័យដែលបណ្តាលមកពីលំហូរចូលនៃមូលធនតាមរយៈក្របខ័ណ្ឌគោលនយោបាយដែលអាចឆ្លើយតបបានឆាប់រហ័សជាងមុន ។

១០. តាមរយៈក្របខ័ណ្ឌគោលនយោបាយក្នុងស្រុក និងទ្រនាប់ការពាររឹងមាំជាងមុន ការបន្តពង្រឹងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុរវាងបណ្តាសេដ្ឋកិច្ចនានាក្នុងតំបន់អាស៊ានបូកបី នឹងជួយបង្កើនភាពធន់ចំពោះការប៉ះទង្គិច ព្រមទាំងអនុញ្ញាតឱ្យសេដ្ឋកិច្ចទាំងនេះរក្សាបាននូវកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយចីរភាព។